82/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ៣៧៥
ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥
សាលដីកា
លេខ : ៣៩២ "ដ"
ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៣

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាំសវនាការជាសាធារណៈនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣។

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

ដើមចោទៈលោក [redacted] វណ្ណា (ម្ចាស់បណ្ដឹងសាទុក្ខ) អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ សព្វថ្ងៃភូមិអណ្ដូងពោធិ៍ ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។

មេធាវី : លោក [redacted] តំណាងដោយអាណត្តិ

ចុងចម្លើយៈលោក [redacted] ឈឹម (ម្ចាស់បណ្ដឹងសាទុក្ខ) អាយុ ៥៦ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅ សព្វថ្ងៃ ភូមិកណ្ដាល ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។



មហាវិថី សម្ដេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia



Scanned with CamScanner

កម្មវត្ថុបណ្តឹង :-ប្តឹងសុំមោឃៈភាពកិច្ចសន្យា ១៣-០៧-២០០០
-ប្តឹងសុំឱ្យអនុវត្តកិច្ចសន្យា ១៣-០៧-២០០០

## អង្គហេតុ និង ចំណុចវិវាទ:

ក-អង្គហេតុជាមូលហេតុនៃការវិវាទ:

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ របស់ឈ្មោះ[redacted] វន្ថា បានប្តឹងសុំមោឃៈភាពកិច្ច-សន្យា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០០ រវាងខ្លួន និង ឈ្មោះ [redacted] ឈឹម ដោយហេតុថា ខ្លួនទីទ័លពេក ខ្លួនធ្វើដោយមិនយល់ ដោយមានការភ័ន្តច្រឡំ និង ត្រូវទទួលការគំរាមបំភិតបំភ័យពីលោក[redacted] ឈឹម ធ្វើអោយខ្លួនបង្ខំចិត្តផ្តិតមេដៃលើកិច្ចសន្យា ចុះថ្ងៃទី ១៣-០៧-២០០០ ដែលមានទឹកប្រាក់ចំនួន ៧០៨៦$ (ដុល្លារអាមេរិក) ដោយខ្លួនបានទទួលប្រាក់សុទ្ធចំនួន ៣.៥០០ដុល្លា(ដុល្លារអាមេរិក) ពីឈ្មោះ[redacted] ឈឹម ហើយខ្លួនបានបង់ការប្រាក់ជូនឈ្មោះ [redacted] ឈឹម អស់ចំនួន ២៧ខែ គឺស្មើនឹងទឹកប្រាក់ ៤.២២១.៧២ដុល្លារអាមេរិក ។

តាមពាក្យបណ្តឹងសារទ្រឡប់ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ឈ្មោះ[redacted] ឈឹម ប្តឹងសុំអោយឈ្មោះ [redacted] វន្ថា អនុវត្តកិច្ចសន្យា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០០ រវាងខ្លួន និង[redacted] វន្ថា ដោយសំអាងហេតុថា នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០០ ឈ្មោះ [redacted] វន្ថា បានចុះកិច្ចសន្យាខ្ចីចងការប្រាក់ខ្លួនសរុបទាំងអស់ ៧០៨៦ដុល្លាអាមេរិក បូករួមទាំងប្រាក់ជំពាក់ថ្លៃទំនិញ ៣៩០ដុល្លាអាមេរិកផងដែរ ដោយបានគិតការប្រាក់ ៣% ក្នុងមួយខែ ហើយបានដាក់បញ្ចាំប័ណ្ណសំគាល់សិទ្ធិលេខ ៣ហ.០០០០៦២ ចុះថ្ងៃទី ០១-១២-១៩៩៩ ដោយបញ្ជាក់ថា ដាក់ដីទំហំ ១០.៥០ម គុណ ៣៥ម ហើយកន្លងមក[redacted] វន្ថា មិនបានអនុវត្តកិច្ចសន្យាទេ ។ ដូច្នេះ ខ្លួនសុំអោយ[redacted] វន្ថា អនុវត្តកិច្ចសន្យា និង ទារជំងឺចិត្ត ៤.០០០ដុល្លា សម្រាប់ជួសជុលការខូចខាតផលប្រយោជន៍របស់ខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៥ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ សាលាដំបូងខេត្តព្រះវិហារ សំរេច:

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ របស់ឈ្មោះ[redacted] វន្ថា (កូនបំណុល) ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។ តាមមាត្រា ១៥ នៃច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

២-ទទួលពាក្យបណ្តឹងសារទ្រឡប់ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ របស់ឈ្មោះ [redacted] ឈឹម (ម្ចាស់បំណុល) ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣-បង្គាប់អោយឈ្មោះ[redacted] វន្ថា (កូនបំណុល) សងប្រាក់ចំនួន ៧០៨៦ដុល្លារអាមេរិក( ប្រាំពីរពាន់ប៉ែត

សិបប្រាំមួយដុល្លាអាមេរិក) អោយឈ្មោះ[redacted] ឈឹម បើគ្មានប្រាក់សង ត្រូវរឹបអូសដីទំហំ ១០.៥០ម គុណ ៣៨ម ប៉ែកខាងលិចតាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣ហ.០០០០៦២ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៩ មានព្រំប្រទល់ខាងកើតជាប់ប៉ែកខាងកើតនៃប្លង់ ខាងលិចជាប់ដី [redacted] ហូ , ខាងជើងជាប់ផ្លូវ, ខាងត្បូងជាប់ដី [redacted] សំអាត ស្ថិតនៅភូមិអណ្តូងពោធិ៍ ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ លក់ឡាយឡុងដើម្បីធានាសំណង។ ក្នុងករណីរឹងរូស ត្រូវដាក់គុកបង្ខំលើរូបកាយតាមច្បាប់។ ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី។

៤-បង្គាប់អោយឈ្មោះ[redacted] វន្ថា បង់ប្រាក់ជម្ងឺចិត្តអោយឈ្មោះ[redacted] ឈឹម ចំនួន ២០០០ដុល្លាអាមេរិក។ ការទាមទារលើសពីនេះលើកចោល។

៥-ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ កិច្ចការប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ។ កាលបើហួសបណ្តឹងឧទ្ធរណ៍ បង្គាប់អោយបង់ពន្ធសមាមាត្រ ១% លើទឹកប្រាក់ ៧.០៨៦ដុល្លាអាមេរិក និង ប្រាក់ជម្ងឺចិត្ត ២០០០ដុល្លាអាមេរិក សរុប ៩.០៨៦ដុល្លាអាមេរិក ស្មើ ៩០.៨៦ ដុល្លាអាមេរិក។

ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០% រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ពន្ធសមាមាត្រនេះ ត្រូវឱ្យឈ្មោះ[redacted] ឈឹម បង់មុន ទើបបង្គាប់អោយឈ្មោះ[redacted] វន្ថា សងទៅឈ្មោះ [redacted] ឈឹម ជា ក្រោយ។

៦-សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះម្ចាស់បណ្តឹងសារត្រឡប់ឈ្មោះ[redacted] ឈឹម កំបាំងមុខដើមចោទឈ្មោះ [redacted] វន្ថា និង មេធាវីដើមចោទ តែចាត់ទុកជាចំពោះមុខ សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

*សាលក្រមនេះត្រូវបានឈ្មោះ [redacted] ឈឹម ប្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ០៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៤ ត្រង់ចំណុចទី ៤ នៃសាលក្រម ។*

*សាលក្រមនេះត្រូវបានឈ្មោះ[redacted] វន្ថា ប្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ០៣ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៤ ត្រង់ចំណុចទាំងមូលនៃសាលក្រម ។*

បានឃើញសាលដីកាបរដ្ឋប្បវេណីលេខ ៦០"ឈ"ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៥ របស់ សាលាឧទ្ធរណ៍ សំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ[redacted] វន្ថា ទុកជាត្រឹមត្រូវ



Scanned with CamScanner

៨២/៤

តាមទម្រង់ និង គតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ [redacted] ឈឹម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ តុលាការខេត្តព្រះ-វិហារ ចោលជាអសារបង់ ។

៤-ទុកជាមោឃៈកិច្ចសន្យាបញ្ចាំដី ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០០ រវាងឈ្មោះ [redacted] វន្ថា និង ឈ្មោះ [redacted] ឈឹម ។

៥-បង្គាប់អោយឈ្មោ[redacted] វន្ថា សងប្រាក់ដើមចំនួន ១៣៨០.២៨ដុល្លាអាមេរិក(មួយពាន់បីរយប៉ែតសិបដុល្លា និង ម្ភៃប្រាំបីសេន) និង ការប្រាក់ ៩% ក្នុងមួយឆ្នាំលើប្រាក់ដើមចំនួន ៩.៦០២ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០០ រហូតដល់ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ និង ការប្រាក់ ៩% លើប្រាក់ដើមចំនួន ១.៣៨០.២៨ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ រហូតដល់ថ្ងៃទូទាត់បំណុលរួច និង ជម្ងឺចិត្តចំនួន ២.០០០ដុល្លាអាមេរិក (ពីរពាន់ដុល្លាអាមេរិក) អោយទៅឈ្មោះ [redacted] ឈឹម ចាប់ពីពេលដែលសាលដីកាចូលជាស្ថាពរ ។ សំណូមពរលើសពីនេះបដិសេធចោល ។

-បើគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងដើម្បីជានាសំណង ។

-ក្នុងករណីរឹងរូស ត្រូវដាក់គុកបង្ខំរូបរាងកាយតាមច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៦-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៩៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និង លើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល និង បង្គាប់អោយដើមចោទបង់ពន្ធសមាមាត្រ ១% លើប្រាក់ដែលត្រូវសង ។

៧-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ចំពោះមុខដើមចោទ និង តំណាងចុងចម្លើយ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៥ ចំពោះមុខដើមចោទ និង តំណាងចុងចម្លើយ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] វន្ថា ប្តឹងសាទុក្ខ តាមបណ្តឹងលេខ ១៩៥ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រង់ចំណុចនៃសេចក្តី សំរេចទាំងមូល ។*

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ឈឹម ប្តឹងសាទុក្ខ តាមបណ្តឹងលេខ ២៦១ ចុះថ្ងៃទី ០៨ ខែ កក្កដា*



Scanned with CamScanner

82/3

ឆ្នាំ ២០០៥ ត្រង់ចំណុចនៃសេចក្តី សំរេចទាំងមូល ។

## ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគី :

ឈ្មោះ [redacted] វិន្នា ធ្វើសេចក្តីថ្លែងការណ៍ថា : នៅចន្លោះឆ្នាំ ៩៥ ខ្លួនជាអតីតកងទ័ព និង ពិការជើង ក៏បានទំនាក់ទំនងជាមួយចុងចម្លើយបានខ្ចីប្រាក់ ២.០០០ដុល្លា ធ្វើដើមរកស៊ី ដោយពុំបានដាក់ទ្រព្យបញ្ចាំទេ ដោយជឿងតាមចុងចម្លើយថា ខ្លួនមានដីនៅជិតផ្សារ បើគ្មានលុយសងគាត់ អាចជូលដីខ្លួន និង កាត់ប្រាក់ឈ្នួល ជាសំណងប្រាក់ដែលខ្លួនជំពាក់ ។ ក្រោយមកខ្លួនគ្មានប្រាក់បង់អោយគាត់ ហើយត្រូវគាត់គំរាមថានឹងប្តឹងខ្លួនទៅតុលាការ ។ ក្រោយមកគាត់បែរជាធ្វើកិច្ចព្រមព្រៀងថា ខ្លួនលក់ដីអោយគាត់តម្លៃ ៩.០០០ដុល្លា ដោយមានភូមិឃុំដឹងឮ ក្រោយមកទៀត គាត់ថា កិច្ចព្រមព្រៀងនេះមិនយកជាបានការទេ ។ ចុងចម្លើយបានអោយខ្លួនយកប័ណ្ណសំគាល់សិទ្ធិចូលទៅតុលាការ ដើម្បីធ្វើកិច្ចសន្យាថ្មី ពេលចូលតាម ស្រាប់តែឃើញចុងចម្លើយសរសេរចំនួនប្រាក់ជំពាក់គាត់ដល់ទៅ ៧០៨០ដុល្លា ដែលជាតួលេខខ្យល់ផង និង ពិតផង និង បានធ្វើកិច្ចសន្យាខ្ចីប្រាក់គាត់ជាង ៥ ពាន់ដុល្លាទៀត ។ ខ្លួនសុំបញ្ជាក់ថា ខ្លួនបានខ្ចីប្រាក់ដើមចោទតែពីរលើកប៉ុណ្ណោះ គឺ ២.០០០ដុល្លា និង ១.៥០០ដុល្លា និង ប្រាក់ថ្លៃទំនិញជាង ៣៩០ដុល្លា ។ ក្នុងទឹកប្រាក់ដែលជំពាក់នេះ ខ្លួនសងការប្រាក់បានជាង ៤.២០០ដុល្លា ។

ខ្លួនព្រមសតាមការសំរេចអោយសងប្រាក់ ១.៣៨០.២៨ដុល្លាហើយ ចំពោះចំណុចការប្រាក់ និង ជម្ងឺចិត្ត ២.០០០ដុល្លា ខ្លួនមិនយល់ព្រមទេ ។

ឈ្មោះ [redacted] ឈឹម ធ្វើសេចក្តីថ្លែងការណ៍ថា : សាលាឧទ្ធរណ៍សំរេចបាត់ផលប្រយោជន៍ខ្លួនច្រើនពេក ។ ខ្លួន និង ដើមចោទជាយោធិនដូចគ្នា ពេលរំសាយមក គាត់បានខ្ចីប្រាក់ខ្លួន ដោយមានស៊ុរិយោដីចូលរួមផង ។ ខ្លួនសុំបញ្ចប់ត្រឹមនេះ ដោយសុំទទួលយកការតាមការសំរេចរបស់សាលាឧទ្ធរណ៍ ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយ ដើមចោទ ធ្វើសេចក្តីថ្លែងការណ៍ថា : កិច្ចសន្យាមានវិការៈ ម្ចាស់បំណុលកេងយកចំណេញលើសលុប ទើបខ្លួនជាមេធាវីបានដាក់ពាក្យបណ្តឹងសុំមោឃៈកិច្ចសន្យានេះ ។ កូនក្តីខ្លួនខ្ចីប្រាក់ចុងចម្លើយសរុបតែ ៣៨៩០ដុល្លា ហើយសងការប្រាក់បាន ៤.២២១.៧២ដុល្លា ដូច្នេះ បើដកទៅឃើញថា កូនក្តីខ្លួនសងលើសប្រាក់ដើមទៅទៀត ។

ចំណុចទី ៥ នៃសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ គឺមិនត្រឹមត្រូវទេ ។ ដូច្នេះ ខ្លួនសុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ។ ទឹកប្រាក់ ៥ពាន់ជាងដែលសាលាឧទ្ធរណ៍យកមកដកប្រាក់ការ ៤២២១.៧២ដុល្លា មិនដឹងចេញមកពីប្រភពណាទេ ចុងចម្លើយគួរតែបង្វិលប្រាក់ដែលបង់លើសអោយកូនក្តីខ្លួន និង ប្រាក់ជម្ងឺចិត្ត ២.០០០ដុល្លាមកឱ្យ



Scanned with CamScanner

កូនក្តីខ្លួន ព្រោះកូនក្តីខ្លួនពុំដែលមានអន្ទះរោកប្រាស់គេទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ គូក្តី និង សេចក្តីថ្លែងការណ៍របស់មេធាវី ដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៩៥ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ របស់ឈ្មោះ [redacted] វិន្នា និង បណ្តឹងសាទុក្ខលេខ ២៦១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥ របស់ឈ្មោះ [redacted] ឈឹម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ៥៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា នៅចំពោះមុខសវនាការតុលាការកំពូល គូភាគីបានទទួលស្គាល់ថា បច្ចុប្បន្នប្រាក់ដើមមានចំនួន ១៣៨០,២៨ដុល្លាអាមេរិក ហើយដើមចោទយល់ព្រមសងប្រាក់ចំនួន ១៣៨០,២៨ដុល្លាអាមេរិក នេះទៅអោយចុងចម្លើយ។

-យល់ឃើញថា ការសំរេចរបស់សាលាឧទ្ធរណ៍លើការប្រាក់ ៥% ក្នុងមួយឆ្នាំ លើប្រាក់ដើម ៥.៦០២ ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០០ រហូតដល់ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ និង ការប្រាក់ ៥% លើប្រាក់ដើម ១៣៨០,២៨ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ រហូតដល់ថ្ងៃទូទាត់បំណុលរួចនោះ មិនត្រឹមត្រូវទេ ពីព្រោះប្រាក់ដើមគូភាគីទទួលស្គាល់តែ ១៣៨០,២៨ដុល្លាអាមេរិកប៉ុណ្ណោះ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយចុងចម្លើយបង់ជម្ងឺចិត្ត ២.០០០ដុល្លា ទៅដើមចោទនោះ សាលាឧទ្ធរណ៍មិនទាន់បានបាន់ស្មានពីព្យសនកម្មនៅឡើយ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦០"ឈ" ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៥ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ ។

## ហេតុដូចនេះ

## ស ម្រេ ច

១-ទទួលផ្នែកខ្លះ នៃបណ្តឹងសាទុក្ខលេខ ១៩៥ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ របស់ឈ្មោះ [redacted] វិន្នា



Scanned with CamScanner

៤៧/1

និង ច្រានចោលបណ្ដឹងសាទុក្ខលេខ ២៦១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥ របស់ឈ្មោះ [redacted]ឃីម ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦០ "ឈ" ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៥ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចជម្ងឺចិត្ត និង ការប្រាក់ដើម លើប្រាក់ដើមចំនួន ៥៦០២ ដុល្លារអាមេរិក ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៣៧៥ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ របស់ តុលាការកំពូលទៅ សាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ លើចំណុចសំណងជម្ងឺចិត្ត និង ការប្រាក់ ។

៤-ប្រាក់ប្រដាប់ក្ដីជាន់តុលាការកំពូលជាបន្ទុករបស់ គូក្ដី ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ ។

| | | |
|---|---|---|
| ឯកឧត្ដម | [redacted] | ប្រធាន |
| លោកស្រី | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានយើញ

ភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៣

ប្រធាន

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner